ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ
លេខៈ ០០៤/១៩ ក.ជ

# គោរពជូន
## លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍
## នៃគណៈកម្មាធិការជាតប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

ជាទីគោរព

**<u>តាមរយៈ</u>**៖ លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃ គ.ជ.ប.ជ

**<u>កម្មវត្ថុ</u>**៖ សូមគោរពស្នើសុំអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ រៀបចំបទបង្ហាញស្តីអំពី៖ «ការណែនាំ និងប្រើប្រាស់ប្រព័ន្ធប្រមូលព័ត៌មានដៃគូអភិវឌ្ឍន៍ លើសេវាកម្មសម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទនៅលើគេហទំព័រវិបសាយ និងកម្មវិធី App នៅលើទូរស័ព្ទ»។

ឯកសារ ៣
29/01/19

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពជម្រាបជូន **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបថា ៖ ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិកន្លងមកធ្លាប់បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ (Chab Dai Coalitions) រៀបចំសិក្ខាសាលាប្រមូលធាតុចូលសម្រាប់រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព័ត៌មានដៃគូអភិវឌ្ឍន៍លើសេវាកម្មសម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលបង្កើតដោយក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិចំនួនពីរដងរួចមកហើយ ដែលលើកទី១ បានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១៤:00 រសៀល នៅភោជនីដ្ឋានទន្លេបាសាក់២ និងលើកទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង ១៤:00 រសៀល នៅអគារ International Christian Fellowship (CFI)។ គោលបំណងនៃការរៀបចំបទបង្ហាញ និងណែនាំពីរបៀបប្រើប្រាស់នៅលើកទី៣នេះ គឺដោយយល់ឃើញថា មានអង្គការមួយចំនួនបានរៀបចំបញ្ចូលព័ត៌មានរបស់ខ្លួនរួចរាល់ទៅក្នុងទម្រង់ចុះបញ្ជីអង្គការដែលផ្តល់អោយដោយ គ.ជ.ប.ជ ហើយក៏បានផ្ញើព័ត៌មានទាំងនោះមកកាន់ គ.ជ.ប.ជ រួចរាល់ហើយដែរ។ ក្រុមការងារ បានធ្វើការបញ្ចូលសាកល្បងទៅក្នុងគេហទំព័រវិបសាយខាងលើរួចហើយ ។ ក្នុងន័យនេះដែរ សិក្ខាសាលាលើកទី៣ យើងខ្ញុំនឹងធ្វើការផ្សព្វផ្សាយសមិទ្ធផលថ្មីនេះ តាមរយៈការធ្វើបទបង្ហាញ និងណែនាំអោយកាន់តែច្បាស់អំពីរបៀបប្រើប្រាស់វិវសាយនេះ ។ សមិទ្ធិផលនេះ នឹងផ្តល់សារៈសំខាន់ ក្នុងការគ្រប់គ្រងទិន្នន័យរបស់ដៃគូទាំងឡាយ ដែលមានសេវាកម្មជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់រូបភាព។

អាស្រ័យហេតុនេះសូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាប និងសម្រេចដ៏ខ្ពង់ខ្ពស់។

បានឃើញ និងគោរពជូន
**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**
មេត្តាពិនិត្យ និងសម្រេចដោយក្តីគោរព។
ថ្ងៃ.........ខែ.........ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី..២៨..ខែ..មករា..ឆ្នាំ២០១៩
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក រេជ្ជ.ប៉ុណ្ណ សំខាន់

ថ្ងៃ.........ខែ.........ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី..២៨..ខែ..មករា..ឆ្នាំ២០១៩
**អគ្គលេខាធិការរង**
**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

នៃ_សិរីលក្ខិណា